**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៣ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធមិ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការវិវិភាករណ៍អនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមការចាំបាច់ ក្នុងការកែទំរង់ប្រព័ន្ធយុត្តិធមិរបស់រាជរដ្ឋាភិបាល និងយោងទៅតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធមិ

## **សំ រេ ច**

**ប្រការ១ :** ត្រូវបានបង្កើត "ក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" ហៅកាត់ថា "ក្រុមការងារ ក.យ.ឧ.ក្រ.ច." សំរាប់ជួយរដ្ឋមន្ត្រី ក្នុងទំនាក់ទំនងការងារជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការប្រព្រឹត្តទៅរបស់ខ្លួន ។

**ប្រការ២ :** "ក្រុមការងារ ក.យ.ឧ.ក្រ.ច." នេះមានតួនាទី និងភារកិច្ចដូចតទៅ :

- ធ្វើទំនាក់ទំនង និងសម្របសម្រួលកិច្ចការរវាងក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំដៅធ្វើឱ្យដំណើរការ នៃប្រព័ន្ធតុលាការប្រព្រឹត្តទៅបានល្អប្រសើរ និងឯកភាពគ្នា ។
- ទទួលបន្ទុកគ្រប់កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។
- ទទួលបន្ទុករៀបចំធ្វើរបាយការណ៍ កំណត់ហេតុ នៃកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងថែរក្សាទុកនូវរបាយការណ៍ កំណត់ហេតុទាំងនោះ ព្រមទាំងឯកសារផ្សេងៗទៀត ។

**ប្រការ៣ :** "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ដឹកនាំដោយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាប្រធាន រដ្ឋលេខាធិការមួយរូបជាអនុប្រធាន និងមានសមាជិកមួយចំនួនជាសេនាធិការតាមការចាំបាច់ ហើយដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ ។

**ប្រការ៤ :** "ក្រុមការងារ ក.យ.ឧ.ក្រ.ច." មានពីរផ្នែកគឺ : ផ្នែករដ្ឋបាល-ហិរញ្ញវត្ថុ និងផ្នែកជំនួយកិច្ចការតុលាការ ។

**ប្រការ៥ :** ប្រធានផ្នែក អនុប្រធានផ្នែក មន្ត្រីបុគ្គលិកនៃ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**ប្រការ៦ :** មន្ត្រី បុគ្គលិក នៃ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." មានប្រាក់បៀវត្ស ដូចមន្ត្រី បុគ្គលិក ដែលមានថ្នាក់ស្មើគ្នារបស់ក្រសួងយុត្តិធម៌ និងមានប្រាក់ឧបត្ថម្ភផ្សេងៗ ដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**ប្រការ៧** : ថវិកាសំរាប់ដំណើរការនៃ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ត្រូវគ្រោងក្នុងថវិកាជាតិ ដែលស្ថិតនៅជាកញ្ចប់ថវិកាមួយដោយឡែក នៃថវិកាក្រសួងយុត្តិធម៌ ដែលមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអាណាប័ក ។

**ប្រការ៨** : របាយការណ៍ កំណត់ហេតុ និងឯកសារផ្សេងៗទាំងអស់ របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរក្សាទុកនៅទីស្នាក់ការរបស់ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ដែលមានទីតាំង នៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

សមាជិក សមាជិកា នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសិទ្ធិពិនិត្យមើលរាល់ឯកសារទាំងអស់ ដែលរក្សាទុកនៅក្នុងទីស្នាក់ការរបស់ "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ។

**ប្រការ៩** : "ក្រុមការងារ ក.យ.ឧ.ក្រ.ច." ប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ សំរាប់ដំណើរការការងាររបស់ខ្លួន ។

**ប្រការ១០** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១១** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារសាមី ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច /
- ឯកសារ-កាលប្បវត្តិ